**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ០៧០/១៥ ក.អ.ជ.សរ

ថ្ងៃសុក្រ ៤ រោច ខែ ចេត្រ ឆ្នាំ មមី ព.ស. ២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា គ.ស ២០១៥

# សេចក្តីសម្រេច

# ស្តីពី

# ការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តគម្រោង សាកល្បងផ្ទេរមុខងាររដ្ឋបាលជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងលិខិតលេខ ១២៩២ សហវ.អហក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងលិខិតលេខ០១១ សជណ/គ.ជ.អ.ប. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ ២០១៥ របស់លេខាធិការដ្ឋានគ.ជ.អ.ប.

## សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងក្រុមការងារការអនុវត្តសាកល្បងការផ្ទេរមុខងារអនាម័យជនបទ ដែលមានសមាសភាពដូចខាងក្រោម÷

១-លោកបណ្ឌិត **យ៉ាន់ ម៉ាន់ជីលុច** អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ ជាប្រធាន

២-លោកបណ្ឌិត **ឌី សុចណ្ណា** អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអនុប្រធាន

៣-លោក**សុខ សុទ្ធី** អនុប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ ជាអនុប្រធាន

៥-លោក **ថ្វាយ ម៉ុម** ប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ ជាសមាជិកអចិន្ត្រៃយ៍

៦-លោក **គី សុផល** អនុប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ ជាសមាជិក

៧-លោក **យូច លីនឌី** អនុប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ ជាសមាជិក

៨-លោក **ជា សុជាតិ** អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានរតនាគារជាតិ ជាសមាជិក

៩-កញ្ញា **គង់ ម៉ុណ្ណា** ប្រធានការិយាល័យមុខងាររដ្ឋបាលថ្នាក់ក្រោមជាតិនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ ជាសមាជិក

១០-លោក **ផន ចាន់រិទ្ធ** ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ជាសមាជិក

១១-លោក **ចន ជីវ័ន្ត** ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ជាសមាជិក

**ប្រការ ២.-**

ក្រុមការងារការអនុវត្តសាកល្បងការផ្ទេរមុខងារអនាម័យជនបទ មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- វិភាគ និងកំណត់តួនាទីរបស់អ្នកពាក់ព័ន្ធ ដែលត្រូវអនុវត្តឱ្យបានសមស្រប សម្រាប់បំពេញមុខងារ និងមុខងាររង ស្តីពីអនាម័យជនបទក្នុងដំណាក់កាលសាកល្បងផ្ទេរមុខងារ តាមរយៈការរៀបចំសិក្ខាសាលា និងកិច្ចពិភាក្សាជាមួយអ្នកពាក់ព័ន្ធនានា
- រៀបចំឯកសារបរិយាយពីតួនាទី និងភារកិច្ច (TOR) របស់អ្នកពាក់ព័ន្ធនានា ដើម្បីធានាថា ការបំពេញមុខងារ និងមុខងាររងស្តីពីអនាម័យជនបទក្នុងដំណាក់សាកល្បងផ្ទេរមុខងារ នឹងទទួលបានជោគជ័យ
- កំណត់ធនធាន និងប្រភពធនធានចាំបាច់ក្នុងការបំពេញមុខងារ និងមុខងាររងស្តីពីអនាម័យជនបទ ឱ្យមានប្រសិទ្ធភាព
- ណែនាំស្តីពីការផ្ទេរផ្តល់ការងារ និងធនធាន តាមរយៈជួយសម្របសម្រួលដល់ការរៀបចំផែនការសកម្មភាព និងថវិកា សម្រាប់បំពេញមុខងារ និងមុខងាររងស្តីពីអនាម័យជនបទរបស់រដ្ឋបាលស្រុក និងឃុំគោលដៅ

សម្រាប់រយៈពេលសាកល្បង

- រៀបចំសេចក្ដីព្រាងឯកសារគម្រោង កម្មវិធីគាំទ្រការសាកល្បងផ្ទេរមុខងារស្ដីពីអនាម័យជនបទ
- ពិភាក្សា ពិនិត្យ និងស្វែងរកដំណោះស្រាយសម្រាប់ការអនុវត្តកម្មវិធីគាំទ្រការសាកល្បងផ្ទេរមុខងារស្ដីពីអនាម័យជនបទ

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តគោលដៅ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ជា សុផារ៉ា

**កន្លែងទទួល**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការ គ.ជ.អ.ប.
- រដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត ស្រុកគោលដៅ)
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១ និង ៤

  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ